វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ANZ Royal

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា

ឆ្នាំ២០១៤ លេខ ០៣

## សហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ និង សមាហរណកម្មក្នុងតំបន់: តើមានន័យដូចម្តេចសម្រាប់កម្ពុជា?

"សេដ្ឋកិច្ចមានការប្រកួតប្រជែង និងសន្ទុះខ្លាំង ត្រូវសម្រេចឲ្យបាន ប្រសិនបើកម្ពុជាចង់ចាប់យកឱកាសល្អនៃសមាជិកភាពនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន"

*លោក ហ៊ីង វុត្ថា*

*អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI*

### កម្ពុជា និង សហគមន៍សេដ្ឋកិច្ចអាស៊ាន

នៅឆ្នាំ២០១៥ កម្ពុជានឹងចូលរួមជាមួយប្រទេសអាស៊ីអាគ្នេយ៍ឯទៀតៗដើម្បីបង្កើតទីផ្សារតែមួយគឺ សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)។ សហភាពសេដ្ឋកិច្ចនេះ ជាចំណុចកំពូលនៃទំនាក់ទំនងសេដ្ឋកិច្ច ក្នុងជាងមួយទសវត្សរ៍កន្លងមក រវាងកម្ពុជា នឹងប្រទេសឯទៀតក្នុងតំបន់តាមរយៈក្របខ័ណ្ឌអាស៊ាន។ ជាមួយគ្នានឹងការបង្កើត AEC បណ្តាប្រទេសអាស៊ាន បានដើរទៅមុខមួយជំហានទៀត ដើម្បីឈានទៅលុបបំបាត់របាំងផ្សេងៗ ដែលរាំងចលនាដោយសេរីនៃទំនិញ សេវាកម្ម មូលធន និងកម្លាំងពលកម្ម ក្នុងទូទាំងតំបន់។

AEC ជាសញ្ញាជាក់ស្តែងបង្ហាញពីចេតនារបស់កម្ពុជា និងបណ្តាប្រទេសជាដៃគូសេដ្ឋកិច្ច ដើម្បីលើកកម្ពស់តួនាទីរបស់អាស៊ាន ឲ្យក្លាយជាប្លុកពាណិជ្ជកម្មដ៏លេចធ្លោបំផុតមួយក្នុងពិភពលោក។ AEC តំណាងឱ្យនិន្នាការនៃការកសាងសម្ព័ន្ធភាពរវាង បណ្តាប្រទេសនៅ "លោកខាងត្បូង" និងឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរក្នុងទម្រង់សេដ្ឋកិច្ចពិភពលោក ជាពិសេស ការផ្លាស់ប្តូរប៉ូលនៃការរីកលូតលាស់ ទៅខាង បណ្តាប្រទេសទើបធ្វើឧស្សាហូបនីយកម្មថ្មីៗ។ នាបច្ចុប្បន្នពាណិជ្ជកម្មក្នុងពិភពលោក ភាគច្រើនធ្វើឡើងរវាងបណ្តាប្រទេសនៅ "លោកខាងត្បូង" ហើយនិន្នាការនេះទំនងជានឹងកំណត់នូវ ទិដ្ឋភាពសេដ្ឋកិច្ចសកលនាពេលអនាគត (រូបភាព ១)។

កម្ពុជានឹងទទួលបានអត្ថប្រយោជន៍ជាច្រើន ក្នុងឋានៈជាសមាជិក AEC ដូចជា ផលចំណេញបានពី កំណើន និងភាពសម្បូរបែបនៃពាណិជ្ជកម្ម និងវិនិយោគរបស់ប្រទេសជាសមាជិក AEC, ការធ្វើសមាហរណកម្មបណ្តាញផលិតកម្មចូលទៅក្នុងតំបន់, និងចលនាពលកម្មដោយសេរីក្នុងទូទាំងតំបន់។ឆ្លងតាមការផ្សារភ្ជាប់ខ្លួនទៅនឹងប្លុកពាណិជ្ជកម្មដ៏មានឥទ្ធិពលនេះ កម្ពុជាក៏នឹងអាចកសាងទំនាក់ទំនងសេដ្ឋកិច្ចដ៏មានអំណោយផល ជាមួយមហាអំណាចសេដ្ឋកិច្ចនានាក្នុងពិភពលោកដែរ។ អាស៊ានបានបង្កើតរួចហើយនូវភាពជាដៃគូពាណិជ្ជកម្មសេរី ជាមួយប្រទេសសំខាន់ៗនៅអាស៊ី ហើយ AEC នឹងផ្តល់នូវឱកាសល្អសម្រាប់បង្កើនអន្តរកម្មបែបនេះទៀត។

រូបភាព ១: លំហូរពាណិជ្ជកម្មសកល

សន្ទស្សន៍ (១០០=តម្លៃនាំចេញក្នុងឆ្នាំ២០០១)




ប្រភព: បណ្ឌិត Enrique Aldaz-Carol, សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា នៅថ្ងៃទី ២៧/០៣/១៤ និងយោងតាមតួលេខផែនទីពាណិជ្ជកម្មរបស់ ITC

អត្ថបទនេះ សង្ខេបចេញពី វគ្គទី៣ នៃការពិភាក្សាតាមក្រុម ក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៤។ អ្នកចូលរួមក្នុងវគ្គនេះ រួមមាន លោក Enrique Aldaz-Caroll សេដ្ឋវិទូជាន់ខ្ពស់ នៃធនាគារពិភពលោក ប្រចាំប្រទេសកម្ពុជា, បណ្ឌិត Suthad Setboonsarng ប្រធានមូលនិធិ Nawa chiOne Foundation ប្រចាំទីក្រុងបាងកក និងអតីតមន្ត្រីជាន់ខ្ពស់ផ្នែកសេដ្ឋកិច្ច/ពាណិជ្ជកម្ម អាស៊ាន-ថៃ, លោក ហ៊ីង វុត្ថា អ្នកស្រាវជ្រាវប្រចាំកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI និង លោក David Vichet Van អគ្គលេខាធិការរង នៃសម្ព័ន្ធអ្នកផលិតស្រូវនិងនាំចេញអង្ករកម្ពុជា។ អ្នកសម្របសម្រួលវគ្គនេះគឺ ឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន CDRI និងទីប្រឹក្សានៃរាជរដ្ឋាភិបាលកម្ពុជា។

គេព្យាករណ៍ថា ការផ្លាស់ប្តូរបណ្តាលមកពី AEC នឹងជួយពង្រឹងសេដ្ឋកិច្ចរបស់កម្ពុជាបានយ៉ាងច្រើន ក្នុងនេះ កំណើនការនាំចេញមានដល់ ៥,៣% កំណើនវិនិយោគ ២៤,៨% និង កំណើន ផសស ពិត ៤,៤%។

រដ្ឋាភិបាលកម្ពុជាបានខិតខំអនុវត្តកំណែទម្រង់នានា ដើម្បីទាញយកប្រយោជន៍ឲ្យបានពេញលេញអំពី សមាជិកភាពក្នុង AEC និងស្របតាមការណែនាំនៅក្នុង ផែនទីបង្ហាញផ្លូវទៅកាន់ AEC ឆ្នាំ ២០១៥។រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានកែលំអផ្លូវដែកនិងផ្លូវថ្នល់ និងអនុវត្តកំណែទម្រង់នានា ដើម្បីលុបបំបាត់របាំងរូបវន្ត និងរបាំងជាបទប្បញ្ញត្តិផ្សេងៗ រវាងកម្ពុជា នឹងប្រទេសអាស៊ានឯទៀតៗ។

យោងតាមផែនទីបង្ហាញផ្លូវ កម្ពុជាបំពេញបានជាង ៧0% នៃកំណែទម្រង់ដែលត្រូវអនុវត្តក្នុងឋានៈជាសមាជិក AEC និងស្ថិតនៅលំដាប់ទី៣ ក្នុងតំបន់ បន្ទាប់ពី សិង្ហបុរី និង ម៉ាឡេស៊ី។

បញ្ហាប្រឈមនៅសេសសល់ ដែលអ្នកបង្កើតគោលនយោបាយត្រូវដោះស្រាយឲ្យបានដើម្បីធានាឱ្យកម្ពុជាទទួលបានអត្ថប្រយោជន៍ពី ការធ្វើសមាហរណកម្មទៅក្នុង AEC គឺមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទំនើបដែលតភ្ជាប់ប្រទេសកម្ពុជាបានយ៉ាងល្អ ទៅក្នុងតំបន់, ការធ្វើពិពិធកម្មមូលដ្ឋាននាំចេញ ដើម្បីទាក់ទាញអ្នកប្រើប្រាស់នៅអាស៊ាន, និងការលើកទឹកចិត្តអ្នកនាំចេញឲ្យប្រើប្រាស់យន្តការពាណិជ្ជកម្មផ្លូវការរបស់ AEC។

## ប្រទេសកម្ពុជា ក្នុងលក្ខណៈជា ស្នូលសេដ្ឋកិច្ច

ចក្ខុវិស័យរបស់អ្នកដឹកនាំ AEC គឺជំរុញអាស៊ាន ឲ្យធ្វើសមាហរណកម្មកាន់តែស៊ីជម្រៅ និងមានការតភ្ជាប់គ្នាកាន់តែខ្លាំង។ ទីក្រុងធំៗនឹងត្រូវមានតភ្ជាប់ដោយផ្លូវថ្នល់ ផ្លូវដែក និងការដឹកជញ្ជូនតាមនាវា និងយន្តហោះ។ តំបន់ដាច់ស្រយាល នឹងត្រូវតភ្ជាប់ទៅនឹងទីក្រុង តាមរយៈប្រព័ន្ធដឹកជញ្ជូនទំនើបដែលផ្តល់សេវាមានតម្លៃថោក និងទៀងទាត់អាចទាយទុកបាន។

ការតភ្ជាប់ប្រទេសកម្ពុជាទៅនឹងទីផ្សារក្នុងតំបន់ តាមរយៈប្រព័ន្ធដឹកជញ្ជូនទំនើប នឹងផ្តល់អត្ថប្រយោជន៍ដល់ផលិតករ តាមការកាត់បន្ថយចំណាយប្រតិបត្តិការ និងបង្កើនលក្ខណៈប្រកួតប្រជែងរបស់ផលិតផលកម្ពុជា នៅក្នុងទីផ្សារតែមួយ។ បន្ទុកចំណាយលើការនាំចេញក្នុងឆ្នាំ២០១២ នៅកម្ពុជា មានកម្រិត ៤០% ខ្ពស់ជាង នៅវៀតណាម បើយោងតាមរបាយការណ៍របស់ធនាគារពិភពលោក ដែលធ្វើឲ្យផលិតផលកម្ពុជាមានថ្លៃខ្ពស់ជាងគេ បើធៀបនឹងជម្រើសផ្សេងទៀតក្នុងតំបន់។ ប្រសិនបើ រដ្ឋាភិបាលអាចរុញបញ្ចុះបន្ទុកចំណាយឲ្យដល់ត្រឹមកម្រិតនៅវៀតណាមនោះ ខាងធនាគារពិភពលោកបានព្យាករណ៍ថា សហគ្រាសធុនមធ្យមនឹងបង្កើនផលិតផលរបស់ខ្លួនបានបីដង។

តំណភ្ជាប់កាន់តែប្រសើរជាមួយប្រទេសជិតខាង នឹងអនុញ្ញាតឱ្យសេដ្ឋកិច្ចកម្ពុជាបានចូលរួមក្នុង បណ្តាញផលិតកម្មទាន់ពេលល្មម (Just In-time Production: JIP) នៅក្នុងតំបន់។ JIP ជាលក្ខណៈមួយនៃសេដ្ឋកិច្ចអាស៊ាន ដែលអនុញ្ញាតឱ្យ ទំនិញកម្មន្តសាលអាចផលិតបានលឿន និងចំណាយអស់តិចបំផុត។ លក្ខណៈសំខាន់មួយនៃគំរូផលិតកម្មនេះ គឺការតភ្ជាប់កម្រិតខ្ពស់ និងការសម្របសម្រួលល្អក្នុងខ្សែចង្វាក់ផ្គត់ផ្គង់ ក្នុងនេះ ល្បឿន និងភាពទៀងទាត់អាចទាយទុកបាន ក្នុងទូទាំងខ្សែចង្វាក់ផ្គត់ផ្គង់ គឺសំខាន់បំផុត ដើម្បីឲ្យប្រព័ន្ធនេះដំណើរការបានរលូន។

ការធ្វើសមាហរណកម្មចូលក្នុងបណ្តាញ JIP នឹងបង្កើតតម្រូវការនូវផលិតផល និងដំណើរការឧស្សាហកម្មច្រើនបែបយ៉ាង ព្រមទាំងជំរុញការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្មរបស់កម្ពុជា។ ក្នុងរយៈពេលមធ្យម ជំនាញផ្សេងៗដែលទទួលបានតាមរយៈ ការធ្វើសមាហរណកម្មចូលទៅក្នុងបណ្តាញ JIP នឹងលើកទឹកចិត្តឧស្សាហកម្មមានតម្លៃបន្ថែមខ្ពស់ ឲ្យចូលមកដំណើការនៅកម្ពុជា ព្រោះលក្ខខណ្ឌទីផ្សារបានផ្លាស់ប្តូរក្នុងទូទាំងតំបន់។

ការសម្របសម្រួលឲ្យ ទំនិញអាចហូរចុះឡើងប្រកបដោយប្រសិទ្ធភាព មានន័យថា កម្ពុជាអាចបានចំណេញ ពីកំណើនពាណិជ្ជកម្ម។ ទីតាំងអាស៊ាននៅជិតជាប់នឹង អាស៊ីបូព៌ាដែលជាប៉ូលនៃកំណើនសេដ្ឋកិច្ចសកល មានន័យថា កម្ពុជាមានឱកាសបង្កើតមូលធនបានពី ការផ្លាស់ប្តូរពាណិជ្ជកម្មឆ្លងកាត់តំបន់ ពោលគឺ ក្នុងប្រាំឆ្នាំកន្លងមកនេះ ពាណិជ្ជកម្មបានកើនឡើង ១២% ជារៀងរាល់ឆ្នាំ។

ទីតាំងជាយុទ្ធសាស្ត្ររបស់កម្ពុជានៅចន្លោះ មណ្ឌលប្រសព្វធំៗក្នុងតំបន់គឺ ក្រុងហូជីមិញ និង ក្រុងបាងកក មានន័យថា កម្ពុជាមានទីតាំងល្អ ដើម្បីទទួលបានអត្ថប្រយោជន៍អំពីពាណិជ្ជកម្មឆ្លងកាត់។ អត្ថប្រយោជន៍ទាំងនេះ រួមមាន កំណើនការប្រកួតប្រជែង ប្រាក់ចំណូល និងប្រសិទ្ធភាពក្នុងការផ្តល់សេវាដឹកជញ្ជូន និងកំណើនតម្រូវការនូវសេវាគាំទ្រផ្សេងៗ ដូចជា គណនេយ្យ និងច្បាប់ ជាដើម។

ដើម្បីឲ្យកម្ពុជាអាចក្លាយស្នូលសំខាន់មួយ នៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននោះ អ្នកបង្កើតគោលនយោបាយត្រូវប្រើវិធីសាស្ត្របី ដើម្បីជំនះលើឧបសគ្គនៃសមត្ថភាពមានកម្រិតនៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។

ទី១ ត្រូវបន្តកិច្ចប្រឹងប្រែងកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា បានឈានទៅមុខច្រើនហើយ ជាពិសេសក្នុងការកែលំអផ្លូវថ្នល់ផ្លូវដែកនិងកំពង់ផែ។ដោយឡែកច្រករបៀងសេដ្ឋកិច្ចខាងត្បូង (ADBs Southern economic corridor) បានផ្តល់នូវក្របខ័ណ្ឌគោលនយោបាយ និងមូលនិធិសម្រាប់តភ្ជាប់កម្ពុជា ឲ្យបានកាន់តែប្រសើរជាមួយ វៀតណាម និង ថៃ។

ទី២ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ត្រូវតែមានបំពេញបន្ថែម ដោយការកសាងសេវាភស្តុភារបែបទំនើប និងស្របតាមស្តង់ដារពិភពលោក។ សន្ទស្សន៍ការងារភស្តុភារ (Logistics Performance Index: LPI) ឆ្នាំ២០១២ របស់ធនាគារពិភពលោក បានចាត់ថ្នាក់កម្ពុជានៅលេខ ១០១ ក្នុងចំណោម ១៥៥ប្រទេស ហើយ វៀតណាម នៅលេខ ៥៣ និងថៃ៣៨។សមត្ថភាពទាបផ្នែកភស្តុភារបានប៉ះពាល់ដល់ផលិតករនៅគ្រប់កម្រិតក្នុងទីផ្សារ ដោយបន្ថែមបន្ទុកចំណាយទៅលើការនាំចេញ និងបង្កើតភាពមិនច្បាស់លាស់ក្នុងការផ្តល់សេវា។

បញ្ហាចម្បងមួយ គឺការដាក់បញ្ចូលគ្នានូវ សេវាភស្តុភារនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់។ បច្ចុប្បន្ន សេវាភស្តុភារនៅថ្នាក់មូលដ្ឋាន មានរចនាសម្ព័ន្ធមិនរៀបរយទេ មានតម្លៃនិងពេលកំណត់មិនទៀងទាត់មិនអាចទាយទុកបាន និងមិនមានការតភ្ជាប់ល្អទៅនឹងបណ្តាញភស្តុភារឆ្លងកាត់ព្រំដែន។ នៅព្រំដែន កុងតឺន័រត្រូវតែលើកចេញ និងដាក់ទៅលើយានយន្តខុសៗគ្នា ដែលត្រូវចំណាយអស់ ១០០ដុល្លារថែមទៀតក្នុងមួយកុងតឺន័រ។

ដើម្បីបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារ រដ្ឋាភិបាលត្រូវចាត់វិធានការ ដាក់បញ្ចូលគ្នានូវប្រព័ន្ធដឹកជញ្ជូននៅតាមមូលដ្ឋាន (ជាពិសេស ប្រព័ន្ធនៅតំបន់ដាច់ស្រយាល) ទៅក្នុងបណ្តាញដឹកជញ្ជូន

ថ្នាក់ជាតិ។ ម៉្យាងទៀតគួរបង្កើតយន្តការផ្សេងៗ ដើម្បីកែលំអការផ្ដល់ព័ត៌មានអំពី កិច្ចព្រមព្រៀងដឹកជញ្ជូនឆ្លងកាត់ព្រំដែនអន្តរជាតិ សំដៅលើកកម្ពស់សហប្រតិបត្តិការឆ្លងកាត់ព្រំដែន។ រដ្ឋាភិបាលក៏ត្រូវលើកកម្ពស់ការប្រកួតប្រជែងផ្នែករថយន្តដឹកជញ្ជូន កំពង់ផែ និងការដឹកជញ្ជូនតាមអាកាសដែរ ដើម្បីលើកកម្ពស់ស្តង់ដារសេវា និងជួយឲ្យផលិតករមានជម្រើសលើការផ្តល់សេវានេះ។

ទី៣ កង្វះសមត្ថភាពស្ថាប័ន ដើម្បីអនុវត្តនីតិវិធីគយប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព បានបង្កើនបន្ទុកចំណាយលើប្រតិបត្តិការនិងការយឺតយ៉ាវ។ រដ្ឋាភិបាលបានខិតខំ តម្រឹមនីតិវិធីគយ ស្របតាមផែនទីបង្ហាញផ្លូវទៅកាន់ AEC នៅឆ្នាំ២០១៥ ប៉ុន្តែកង្វះសមត្ថភាពស្ថាប័នសម្រាប់អនុវត្តគោលនយោបាយនៅព្រំដែនបាននាំឲ្យមានការយកកម្រៃក្រៅផ្លូវការ ដែលក្លាយជាចំណាយបន្ថែមមួយទៀតលើផលិតផលរបស់កម្ពុជា។ ដូច្នេះជាការសំខាន់បំផុតដែលរដ្ឋាភិបាលត្រូវជំរុញមន្ត្រីកុំឲ្យយកប្រាក់កម្រៃ "ក្រៅផ្លូវការ"។

## ការធ្វើពិពិធកម្មជំនាញ និងផលិតផល

ក្នុងឋានៈជាសមាជិក AEC ផលិតករនៅកម្ពុជា មានទីផ្សារជាសក្តានុពលដល់ទៅ ៦០០លានអ្នកប្រើប្រាស់។ វាជាភារកិច្ចរបស់អ្នកបង្កើតគោលនយោបាយ ដើម្បីធានាថា សក្តានុពលនេះប្រែក្លាយទៅជាកំណើនពិតៗ ដោយជំរុញ ការនាំចេញចម្រុះដើម្បីបំពេញតាមតម្រូវការទីផ្សារ។

បច្ចុប្បន្ន កម្ពុជានាំចូលផលិតផលប្រើប្រាស់មានតម្លៃបន្ថែមខ្ពស់មកពីប្រទេសអាស៊ានឯទៀត និងនាំចេញផលិតផលកសិកម្ម និងវត្ថុធាតុដើម។ បើសិននិន្នាការនេះមិនផ្លាស់ប្តូរទេ សមាជិកភាពក្នុង AEC នឹងនាំឲ្យមានកំណើនឱនភាពពាណិជ្ជកម្ម។រដ្ឋាភិបាលត្រូវកសាងគ្រឹះសេដ្ឋកិច្ចចម្រុះមួយ ដោយផលិតកម្លាំងពលកម្មមានជំនាញសមស្រប ដែលបំពេញបានតាមតម្រូវការរបស់សហគ្រាសអាជីវកម្មនិងឆ្លើយតបទៅនឹងការផ្លាស់ប្តូរលក្ខខណ្ឌនៃទីផ្សារខាងក្រៅ។

អ្នកជំរុញពិពិធកម្មក្នុងសេដ្ឋកិច្ចនៃប្រទេសជាច្រើន គឺសហគ្រាសខ្នាតតូចនិងមធ្យម (SME) ដូចដែលគេតែងលើកឡើងក្នុងករណី ការផ្លាស់ប្តូរសេដ្ឋកិច្ចនៅប្រទេសចិន។ ដើម្បីប្រើប្រាស់កម្លាំង SMEs នៅកម្ពុជា អ្នកបង្កើតគោលនយោបាយត្រូវដោះស្រាយ បញ្ហាកង្វះជំនាញបច្ចេកវិទ្យា ដើមទុន និងសមត្ថភាពផ្សព្វផ្សាយទីផ្សារក្នុងវិស័យនេះ។ បច្ចុប្បន្ន បណ្តា SMEs នៅកម្ពុជា មិនអាចប្រកួតប្រជែងជាមួយផលិតករនៅប្រទេសជិតខាងទេ ហើយលំហូរចូលផលិតផលនាំចូលមានតម្លៃថោក អាចគំរាមកំហែងដល់ការរីកលូតលាស់របស់ពួកគេ។

រដ្ឋាភិបាលអាចជួយបង្កើនផលិតភាព SMEs តាមការបង្កើតបទបញ្ញត្តិគ្រប់គ្រងរបៀបរបបធ្វើអាជីវកម្ម។ ការកំណត់ស្តង់ដារធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតារាងតុល្យការ ដើម្បីអាចធ្វើសវនកម្មបានត្រឹមត្រូវ នឹងជួយបង្កើនការផ្តល់កម្ចីពីសំណាក់ធនាគារ, លើកទឹកចិត្តការវិនិយោគ, និងផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ការតភ្ជាប់ជាមួយក្រុមហ៊ុនធំៗនៅក្នុងខ្សែចង្វាក់ផលិតកម្មក្នុងតំបន់។

ជាការសំខាន់ណាស់ដែល បទប្បញ្ញត្តិនានាមានបំពេញបន្ថែមដោយសេវាគាំទ្រផ្សេងៗដែលជំរុញយុទ្ធសាស្ត្រ ជ្រៀតចូលទៅក្នុងបណ្តាញផលិតកម្ម រីកចូលទៅក្នុងទីផ្សារថ្មីៗ និងបង្កើនដើមទុនផ្នែកបច្ចេកទេស និងការគ្រប់គ្រង។

កំណើនវិនិយោគផ្ទាល់ពីបរទេស (FDI) នៅផ្ទៃក្នុងអាស៊ាន ដែលរំពឹងថានឹងទទួលបានពី សមាជិកភាពក្នុង AEC, ដំណើរការពិនិត្យតាមដានជាផ្លូវការ, និងកំណើនផលិតភាព, នឹងផ្តល់ទំនុកចិត្តដល់វិនិយោគិនបរទេស និងជួយរួមចំណែកដល់ការបង្កើន FDI នៅក្នុង SMEs។ ប៉ុន្តែ កំណើន FDI ក៏ជាប្រភពនៃហានិភ័យថ្មីៗដែរ។ ដូចបានពិនិត្យឃើញក្នុងវិបត្តិសេដ្ឋកិច្ចឆ្នាំ២០០៩ នៅពេលលក្ខខណ្ឌខាងក្រៅមានការផ្លាស់ប្តូរ វិនិយោគិនបរទេសក៏ឆាប់ផ្អើលរត់ចេញទៅវិញដែរ។ ដូច្នេះជាការសំខាន់ ដែលរដ្ឋាភិបាលត្រូវបង្កើនការត្រួតពិនិត្យ ដើម្បីបានដឹងពីបំណុល FDI និងអាចគ្រប់គ្រងលើការប៉ះទង្គិចផ្សេងៗ។

ដើម្បីផលិតទំនិញសម្រាប់ទីផ្សារ AEC ត្រូវមានជំនាញថ្មីៗ ហើយបញ្ហាប្រឈមមួយចំនួនផ្នែកគោលនយោបាយការងារ ក៏មានផុសឡើងដែរ។ កម្លាំងពលកម្មរបស់កម្ពុជាមិនទាន់បានត្រៀមខ្លួនល្អ ដើម្បីទាញយកចំណេញពីសមាជិកភាពក្នុង AEC នោះទេ ដោយពលករភាគច្រើនគ្មានជំនាញ ឬក៏មានជំនាញមិនសមស្រប។

ចលនាកម្លាំងពលកម្មដោយសេរីក្នុង AEC ផ្តល់នូវឱកាសល្អដើម្បីឈានទៅធ្វើឧស្សាហកម្មថ្មី ព្រោះគេអាចបំពេញកង្វះខាតជំនាញនៅក្នុង ទីផ្សារការងារនៅកម្ពុជាបាន។ ប៉ុន្តែជាការសំខាន់ ដែលត្រូវញ៉ាំងឲ្យមានការផ្ទេរជំនាញទាំងនេះ ទៅឱ្យកម្លាំងពលកម្មកម្ពុជាក្នុងរយៈពេលមធ្យម។

ក្នុងរយៈពេលវែង ការទាក់ទាញ FDI ទាមទារឲ្យមានពលករកម្ពុជាមានជំនាញខ្ពស់ ប៉ុន្តែបច្ចុប្បន្ននេះ ធនធានមនុស្សកម្ពុជាមានសមត្ថភាពខ្សោយក្នុង មុខវិជ្ជាស្នូលផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (មុខវិជ្ជា STEM)។ បញ្ហានេះត្រូវដោះស្រាយឲ្យបាន បើសិនប្រទេសកម្ពុជាប្រុងឈានទៅផលិត ទំនិញដែលទាមទារនូវសមត្ថភាពបច្ចេកទេសខ្ពស់។

បញ្ហាចម្បងមួយដែលកំណត់ជោគជ័យនៃ ការធ្វើពិពិធកម្មចូលទៅក្នុងឧស្សាហកម្មថ្មីៗ គឺសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីតភ្ជាប់តម្រូវការរបស់វិស័យឯកជន, ការផ្លាស់ប្តូរនៃលក្ខខណ្ឌខាងក្រៅ និងគោលនយោបាយអប់រំ។ អាជីវកម្មខ្នាតតូចនិងមធ្យមជាច្រើននាពេលបច្ចុប្បន្ន កំពុងខ្វះខាតព័ត៌មានអំពីលក្ខខណ្ឌទីផ្សារខាងក្រៅ និងការប្រែប្រួលផ្សេងៗនៅពេលមាន AEC។

សព្វថ្ងៃនេះ គឺមានការដាច់ចេញពីគ្នារវាង តម្រូវការបច្ចុប្បន្ននិងទៅអនាគតរបស់សហគ្រាសអាជីវកម្ម នឹងការផ្គត់ផ្គង់កម្លាំងពលកម្មមានជំនាញ។ ដូច្នេះត្រូវមានយន្តការល្អជាងមុន ដើម្បីផ្តល់ព័ត៌មានពីទីផ្សារបច្ចុប្បន្ន ការទាយទុកអំពីការផ្លាស់ប្តូរទៅអនាគតនៅក្នុងអាជីវកម្ម និងដើម្បីផ្តល់ព័ត៌មានពីទីផ្សារនេះទៅដល់ គម្រោងបណ្តុះបណ្តាលនានា។

## ឧបសគ្គរារាំងការទាញយកឱកាសល្អពី AEC

នាបច្ចុប្បន្ន ក្នុងវិស័យឯកជននៅមានការមិនច្បាស់លាស់ មួយចំនួនថាតើ AEC មានពាក់ព័ន្ធអ្វីខ្លះដល់ពួកគេ។ ដូច្នេះជាការសំខាន់ណាស់ដែលរដ្ឋាភិបាលត្រូវបង្ហាញថា ការចាប់អនុវត្ត AEC នៅឆ្នាំ២០១៥ មិនមែនគ្រាន់តែជាការផ្លាស់ប្តូរក្រឡាប់ចាក់នៅក្នុងទំនាក់ទំនងសេដ្ឋកិច្ចផ្ទៃក្នុងអាស៊ានប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការបន្ត នឹងធ្វើឲ្យផ្លូវការឡើងនូវ និន្នាការនៃការបន្សុីសេដ្ឋកិច្ចចូលគ្នាដែលបានកើតមានឡើងក្នុងមួយទសវត្សរ៍កន្លងមកនេះ។

ផលិតករកម្ពុជាបានចូលជាភាគីនៃ កិច្ចព្រមព្រៀងកាត់បន្ថយពន្ធគយជាច្រើន ដូចជា តំបន់ពាណិជ្ជកម្មសេរី (FTA), អាស៊ានបូក៥ ជាដើម ដែលបានរួមចំណែកកាត់បន្ថយជាបន្តបន្ទាប់នូវអត្រាពន្ធគយក្នុងទូទាំងតំបន់អាស៊ានក្នុងទសវត្សរ៍កន្លងទៅនេះ។

បញ្ហាដែលអ្នកបង្កើតគោលនយោបាយ កំពុងប្រឈមមុខសព្វថ្ងៃ គឺធ្វើយ៉ាងណាជំរុញឲ្យក្រុមហ៊ុននាំចេញទទួលយក FTA និងប្រើកិច្ចព្រមព្រៀងទាំងនេះជា ក្របខ័ណ្ឌបឋមនៃពាណិជ្ជកម្មផ្ទៃក្នុងតំបន់។ ដូចក្នុង FTAs ដែលមានស្រាប់ ដែរ សមាជិកភាពក្នុង AEC នឹងផ្តល់ជាប្រយោជន៍ជាក់ស្តែងបាន លុះត្រាតែរដ្ឋាភិបាលមានជោគជ័យក្នុងការពង្រីកនិងជំរុញវប្បធម៌មួយដែលទទួលយកការប្រើប្រាស់យន្តការពាណិជ្ជកម្មផ្លូវការ នៅក្នុងសេដ្ឋកិច្ចទាំងមូល។

វង្វាស់ដ៏សំខាន់មួយនៃឧបសគ្គរាំងការអនុវត្ត AEC គឺកំហិតផ្សេងៗលើ អាស៊ានបូក៥ ពីព្រោះកិច្ចព្រមព្រៀងទាំងពីរនេះលើកកម្ពស់ពាណិជ្ជកម្ម តាមរយៈក្របខ័ណ្ឌកាត់បន្ថយពន្ធគយដូចគ្នា។

នាបច្ចុប្បន្នមានតែ ៤៧% នៃពាណិជ្ជកម្មកម្ពុជាប៉ុណ្ណោះដែលហូរតាមក្របខ័ណ្ឌ អាស៊ានបូក៥ ទោះបីវាមានរបបពន្ធគយទាបជាងក្តី ដោយហេតុថា អត្រាសន្សំសំចៃសម្រាប់ផលិតករ ក្នុងការប្រើ អាស៊ានបូក៥ និងប្រេកពាណិជ្ជកម្មផ្សេងទៀត (ឧទាហរណ៍ ក្របខ័ណ្ឌប្រទេសទទួលបាន លក្ខខណ្ឌអនុគ្រោះបំផុតរបស់ កម្ពុជា ឡាវ មីយ៉ាន់ម៉ា វៀតណាម (CLMV)) មានតិចតួចណាស់។

អត្រាពន្ធគយទាបវាបាត់ផលប្រយោជន៍អស់ ដោយសារតែការចំណាយ និងបញ្ហាស្មុគស្មាញផ្សេងៗ ក្នុងការអនុវត្តតាមលក្ខណៈវិនិច្ឆ័យរបស់ អាស៊ានបូក៥។ គេហៅរបាំងដែលរាំងដំណើរការក្របខ័ណ្ឌពាណិជ្ជកម្មសេរីទាំងនេះថា វិធានការមិនមែនពន្ធគយ (Non Tariff Measures: NTMs)។

NTMs ធំបំផុតដែលរារាំងផលិតករកម្ពុជា ក្នុងការប្រើប្រាស់ក្របខ័ណ្ឌអាស៊ានបូក៥ គឺ ការទាមទារឲ្យមានអាជ្ញាប័ណ្ណនាំចេញ។ ក្នុងចំណោម ៤៩ ប្រទេសដែលអនុវត្ត NTMs មានតែ កម្ពុជា និងស្រីលង្កា ប៉ុណ្ណោះ ដែលតម្រូវឱ្យមានអាជ្ញាប័ណ្ណនាំចេញ។

NTMs មិនមែនជាបញ្ហាចោទសម្រាប់តែប្រទេសកម្ពុជាមួយនោះទេ។ ដូចមានបង្ហាញក្នុង រូបភាព ២ ការយកប្រាក់កម្រៃផ្សេងៗបានប៉ះពាល់ដល់ផលិតផលក្នុងទូទាំងអាស៊ាន ហើយអាចបង្កើនបន្ទុកចំណាយដល់ទៅ ២១% ក្នុងករណីមួយចំនួន។ បញ្ហាចោទក្នុងទូទាំងតំបន់នេះ វាជាឧបសគ្គចម្បងដល់ការធ្វើពាណិជ្ជកម្មសេរី។

ដើម្បីឲ្យកម្ពុជា និងប្រទេសឯទៀតក្នុងតំបន់ ទទួលបានអត្ថប្រយោជន៍ពី AEC ដែលជាទីផ្សារតែមួយនេះ គេត្រូវ លុបបំបាត់ NTMs និងតម្រឹមលក្ខណៈវិនិច្ឆ័យសម្រាប់ចូលទៅក្នុង AEC ដើម្បីកុំឲ្យផលិតករបាក់ទឹកចិត្តក្នុងការប្រើប្រាស់ក្របខ័ណ្ឌនេះជា យានសម្រាប់ធ្វើពាណិជ្ជកម្ម។ អ្នកបង្កើតគោលនយោបាយនៅកម្ពុជា គួរតែដោះស្រាយបញ្ហានេះនៅកម្រិតជាតិនិងតំបន់:គោលនយោបាយនានាគួរផ្តោតលើការលុបបំបាត់ NTMs ដ៏ជាក់លាក់របស់កម្ពុជា ប៉ុន្តែក៏ត្រូវជំរុញឲ្យប្រទេសអាស៊ានដទៃទៀត តម្រឹមដំណើរការផ្សេងៗជួយសម្រួលដល់ ពាណិជ្ជករដែលមានបំណងចូលទៅក្នុង AEC ដែរ។

រូបភាព ២: វិធានការមិនមែនពន្ធគយ (NTMs) ក្នុងអាស៊ាន




ប្រភព: បណ្ឌិត Enrique Aldaz-Carol, សន្និសីទស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ថ្ងៃទី ២៧/០៣/១៤ ស្រង់ចេញពីទិន្នន័យរបស់ ASEAN NTM

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ និងមិនមែនជាទស្សនៈរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និង ធនាគារអេអិនហ្សិតរ៉ូយ៉ាល់ ទេ។*

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ (៨៥៥ ២៣) ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥ ២៣) ៨៨០ ៧៣៤

e-mail: cdri@cdri.org.kh, website: www.cdri.org.kh